**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ០១.០៥៥/០៨ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៨

# គ.ជ.ប សុំឱ្យភាគីពាក់ព័ន្ធនឹងការបោះឆ្នោតទាំងអស់ ជួយផ្តល់អនុសាសន៍ លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតឆ្នាំ ២០០៨

នៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានធ្វើសន្និសីទសារព័ត៌មានមួយផ្សព្វផ្សាយសេចក្តីព្រាងបទបញ្ជា និងនីតិវិធី ផ្នែកទី ២ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ ដល់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត ឱ្យផ្តល់អនុសាសន៍លើសេចក្តីព្រាងនេះ ។

ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា គោលបំណងនៃការផ្សព្វផ្សាយសេចក្តីព្រាងបទបញ្ជា និងនីតិវិធី ចាប់ពីជំពូក ៧ ដល់ ១២ គឺដើម្បីឱ្យគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធទាំងអស់ពិនិត្យ និងផ្តល់នូវយោបល់មុននឹង គ.ជ.ប អនុម័តជាផ្លូវការ ។ ឯកឧត្តមបានសំណូមពរឱ្យគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបញ្ជូនអនុសាសន៍របស់ខ្លួន ដែលទាក់ទងនឹងសេចក្តីព្រាងនេះមក គ.ជ.ប វិញ ត្រឹមថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។

បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ចែកជាពីរផ្នែក ហើយផ្នែកទី១ គ.ជ.ប បានអនុម័តរួចរាល់កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧ និងផ្នែកទី២ គ.ជ.ប កំពុងតែចែកចាយសេចក្តីព្រាងដល់ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត ហើយនឹងអនុម័តជាផ្លូវការក្នុងពេលឆាប់ៗខាងមុខនេះ ។

នៅក្នុងសន្និសីទនោះដែរ ឯកឧត្តម អ៊ឹម សួស្តី បានរំលឹកដល់គណបក្សនយោបាយទាំងអស់ ដែលមានបំណងចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើងតាំងតំណាងរាស្ត្រខាងមុខនេះ ឱ្យត្រៀមខ្លួនក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលតាមប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ នឹងចាប់ផ្តើមពីថ្ងៃទី ២៨ ខែមេសា ដល់ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ។ ឯកឧត្តម ក៏បានបញ្ជាក់ឱ្យដឹងដែរថា ចាប់ពីថ្ងៃទី ៥ ដល់ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៨ គ.ជ.ប នឹងធ្វើការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ហើយក្នុងដំណើរការចែកប័ណ្ណព័ត៌មាននេះ គ.ជ.ប សូមឱ្យគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធទាំងអស់ ចូលរួមសង្កេតមើល ដើម្បីឱ្យដំណើរការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

នៅក្នុងសន្និសីទនោះ មានតំណាងគណបក្សនយោបាយចូលរួម ចំនួន ២០ នាក់ តំណាងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ១៣ នាក់ និងអ្នកសារព័ត៌មាន ចំនួន ១៦ នាក់ ។

BtmanbEnmsmTnakTngTrsBe I x³ 023 214 374 / 012 855 018 E-mail: necinfo@forum.org.kh, Web-site : www.necelect.org.kh